សួស្តីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

HAPPY KHMER NEW YEAR

ឯកឧត្តម ឯក សំ អុល

ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

សារជូនពរ

សូមគោរពជូន

ឯកឧត្តម ឯក សំអុល ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ

ឯកឧត្តម ជាទីគោរព!

ក្នុងវិកាសធ៌មហានក្ខត្តឫក្ស ប្រកបដោយក្តីសោមនស្សរីករាយ ក្នុងពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ខាងមុខនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ខ្ញុំបាទនិងភរិយា សូមជូននូវសព្វសាធុការពរជ័យ បវរសួស្តី សិរីមង្គល រៃសុសុខ មហាប្រសើរ ជូន **ឯកឧត្តម** សូមទទួលបាននូវសុខភាពល្អហ្ម្មត ក្លាំងមាំមួន បញ្ញាញាណភ្លឺ ជន្មាយុយឺនយូរ។

ឆ្លៀតក្នុងវិកាសធ៌មហាប្រសើរនេះ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះ: **ឯកឧត្តម** ដែលតែងខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ប្រកបដោយភាពមោះមុតស្មាហ៍ក់ប់ ស្មោះត្រង់ និងការទទួលខុសត្រូវខ្ពស់ក្នុងការបំពេញបេសកកម្មជំនួងនិងតួនាទីឧត្តមប្រយោជន៍ជាតិ សាសនា ព្រះមហាក្សត្រ ព្រមទាំងបានរួមចំណែកយ៉ាងធំធេងជាមួយរាជរដ្ឋាភិបាលក្នុងការការពារនូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍសង្គមជាតិ ឱ្យកាន់តែកែចម្រើនរុងរឿង។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ខ្ញុំបាទនិងភរិយា សូមបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតាឆ្នាំថ្មី ទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះប្រាស់សព្វសាធុការពរជ័យ សិរីមង្គល ជូន **ឯកឧត្តម** និង**លោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម ឯក សំអុល ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពអំពីខ្ញុំបាទ។

ធ្វើនៅឃ្លាំងកណ្តាលនៃខេត្ត ថ្ងៃអង្គារ ០៨កើត ខែមេសា ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០២៦

នាយឧត្តមសេនីយ៍ រ៉ៀ សីហា

វិថីហ្ការ៉ាមីចិត្ត្រា សង្កាត់បឹងត្បូងធ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទូរស័ព្ទ០២៣ ៨៥៣ ២៧៨ email: generalsec@mod.gov.kh